# ប្រាសាទបែបវលភីនៅក្នុងសិល្បៈឥណ្ឌានិងខ្មែរ (ភាគ២)

នៅក្នុងអត្ថបទភាគទី១ ខ្ញុំបានបង្ហាញរួចហើយអំពីទម្រង់ប្រាសាទបែបវលភី ឬប្រាសាទបែបសាលានៅក្នុងសិល្បៈឥណ្ឌា ដែលអត្ថបទនោះល្មមអាចឱ្យយើងយល់បានខ្លះពីទម្រង់ប្រាសាទបែបវលភី ឬប្រាសាទបែបសាលានៅក្នុងស្ថាបត្យកម្មនៃសិល្បៈឥណ្ឌាទាំងខាងជើងនិងខាងត្បូង។ សម្រាប់អត្ថបទនេះ ខ្ញុំនឹងបង្ហាញបន្តអំពីទម្រង់ប្រាសាទបែបវលភី ឬប្រាសាទបែបសាលានៅក្នុងសិល្បៈខ្មែរ វិញម្តង។

សូមរំលឹកផងដែរថា វលភី (Valabhī) ជាពាក្យបច្ចេកទេសនៃស្ថាបត្យកម្មឥណ្ឌាខាងជើង ចំណែកស្ថាបត្យកម្មឥណ្ឌាខាងត្បូងហៅប្រាសាទប្រភេទនេះថា សាលា (Śālā)។ លក្ខណៈទូទៅរបស់ប្រាសាទប្រភេទនេះរួមមាន ជាប្រាសាទទោល មានរាងចតុកោណកែង ដំបូលខាងលើបង្អស់មានរាងកោងវែងមានសណ្ឋានដូចដំបូលទូក។ ហេតុនេះហើយទើបដំបូងមានហោជាងរាងក្រចកសេះទំហំធំនៅចុងដំបូលទាំងសងខាង។ ចំណែកនៅតាមព្រំដំបូលនៃប្រាសាទលម្អដោយកូន**កលស** (Kalaśa) រៀងគ្នាជាជួរ។[៦]

សម្រាប់សិល្បៈខ្មែរ ទម្រង់ប្រាសាទបែបវលភី ឬប្រាសាទបែបសាលានេះយើងឃើញមានវត្តមាននៅក្នុងសិល្បៈខ្មែរតាំងពីសម័យមុនអង្គរមកម្ល៉េះ។ លក្ខណៈប្រាសាទនៅសម័យនោះមានភាពស្រដៀងគ្នាយ៉ាងខ្លាំងទៅនឹងទម្រង់ប្រាសាទបែបសាលានៃសិល្បៈឥណ្ឌាខាងត្បូង។ រហូតមកដល់សម័យអង្គរ ទម្រង់ប្រាសាទប្រភេទនេះបែរជាមានលក្ខណៈខាងស្ថាបត្យកម្មស្រដៀងគ្នាទៅនឹងទម្រង់ប្រាសាទបែបវលភីនៃសិល្បៈឥណ្ឌាខាងជើងទៅវិញ។

ចំពោះប្រាសាទបែបសាលានៅមុនសម័យអង្គរមានការនិយមយ៉ាងខ្លាំង ដូចជាប្រាសាទភ្នំបាយ៉ង់ ប្រាសាទភូមិប្រាសាទ និងប្រាសាទមួយចំនួនធំនៅក្នុងតំបន់សំបូរព្រៃគុក ជាដើម។ លក្ខណៈដោយរួមនៃប្រាសាទទាំងនោះគឺៈ ជាប្រាសាទទោល មានរាងចតុកោណកែង ដំបូលប្រាសាទមានច្រើនជាន់ កើតចេញពីការចម្លងតួប្រាសាទផ្នែកខាងក្រោមដោយបង្រួមឱ្យតូច រួចយកទៅបន្ទុបបន្តពីខាងលើ ត្រួតគ្នាជាថ្នាក់ៗ។ នៅតាមជាន់

[៦] សូមអានបន្ថែមរឿងប្រាសាទបែបវលភីនៅៈ Adam Hardy 2007: 108-110, 176-177។

អត្ថបទដោយៈ ឡេង ស៊ីវ៉ង់

KHMER CIVILIZATION

នីមួយៗនៃដំបូល មានលម្អដោយកូនប្រាសាទរៀងគ្នាជាជួរតាមគ្រប់ជ្រុងទាំង៤។ ចំណែកនៅត្រង់កំពូលដំបូលវិញ បើទោះជាបច្ចុប្បន្នមិនមាននៅសល់ដំបូលដែលល្អបរិបូរក៏ដោយ តែយើងក៏អាចសន្និដ្ឋានបានដែរថា ដំបូលទំនងមានលក្ខណៈកោងដូចដំបូលទូក និងនៅតាមព្រំដំបូលនៃប្រាសាទប្រហែលជាមានលម្អដោយកូន**កលស** (Kalaśa) រៀងគ្នាជាជួរដូចសិល្បៈឥណ្ឌាដែរ (**រូបលេខ១-២**)។ ជាឧទាហរណ៍យើងអាចមើលយល់លក្ខណៈដំបូលបែបនេះបានខ្លះៗពីរូបរាងដំបូលនៃប្រាសាទភូមិប្រាសាទ (**រូបលេខ២**)។ នេះបង្ហាញឱ្យឃើញថា ទម្រង់ប្រាសាទបែបសាលានៃសិល្បៈខ្មែរមុនសម័យអង្គរមានលក្ខណៈដូចគ្នាយ៉ាងខ្លាំងទៅនឹងប្រាសាទបែបសាលានៃសិល្បៈឥណ្ឌាខាងត្បូង ជាពិសេសប្រាសាទសម័យបល្លវៈ។[២] ឧទាហរណ៍ដូចជាប្រាសាទគណេសរថ ជាដើម (**រូបលេខ៣**)។ តែក្រោយមក ការធ្វើប្រាសាទបែបសាលាបែបឥណ្ឌាខាងត្បូងមិននិយមទៀតឡើយនៅសម័យអង្គរ។

នៅក្នុងសម័យអង្គរយើងសង្កេតឃើញមានប្រាសាទមួយក្រុមដែលខ្មែរយើងនិយមហៅថា "បណ្ណាល័យ ឬហោត្រៃ" ច្រើនមានលក្ខណៈជាប្រាសាទទោល មានរាងចតុកោណកែង ដំបូលប្រាសាទច្រើនធ្វើតែមួយជាន់ ហើយដំបូលខាងលើមានលក្ខណៈកោងដូចដំបូលទូក នៅខាងចុងដំបូលទាំងសងខាងជាហោជាងរាងក្រចកសេះ។ នៅអមសងខាងដំបូលកោងនោះមានធ្វើស្វាបដំបូលកោងដើម្បីពង្រីកទំហំនៃសំណង់ (**រូបលេខ៤-៥**)។ ការធ្វើស្វាបដំបូលកោងនៅអមដំបូលមេខាងលើ និងការធ្វើដំបូលតែមួយជាន់នេះជាលក្ខណៈពិសេសដែលយើងឃើញមាននៅក្នុងទម្រង់ប្រាសាទបែបវលភីនៃស្ថាបត្យកម្មឥណ្ឌាខាងជើង(**រូបលេខ៦**)។

ក្រៅពីទម្រង់ស្ថាបត្យកម្មដែលមានលក្ខណៈដូចគ្នាទៅហ្នឹងប្រាសាទបែបវលភីនៃសិល្បៈឥណ្ឌាខាងជើងហើយ យើងនៅប្រទះឃើញបច្ចេកពាក្យ "វលភី" នៅក្នុងសិលាចារឹកខ្មែរមួយចំនួនផងដែរ។ សិលាចារឹកទាំងនោះបានបញ្ជាក់យ៉ាងច្បាស់ថា "វលភី" ជាប្រភេទសំណង់មួយប្រភេទដែលគេបានសាងឡើង។ ជាក់ស្តែងនៅក្នុងសិលាចារឹកស្តុក

---

[២] Chedha Tingsanchali 2016: 55-59.

កក់ធំ K.២៣៥ ចារនៅឆ្នាំ១០៥២ ក្នុងរាជ្យព្រះបាទសូរ្យវម៌្មទី១ បានរៀបរាប់ទាក់ទងនិងការសង់វលភីរហូតដល់ទៅ៤ដង។ ជាឧទាហរណ៍ក្នុងបន្ទាត់ទី២០និងបន្ទាត់ទី៤៧នៃផ្ទាំង "ឃ" មានសេក្តីថា៖

"...វ្រះប្រេកូតាគិ២អាយិដេងវ្នំគិតិចតិស្រុកិថ្វេកាយ៌្យនាវ្រះនោះហ ទំនេប្រចោងប្រាសាទកំវេងវលភិ..." អាចប្រែសម្រួលបានថា "...ទ្រង់ប្រើកូតាស២រូបនោងឯ(វិស័យ)ដើងភ្នំឱ្យចាត់ចែងស្រុក និងធ្វើការបម្រើព្រះ(នៅទី)នោះ ដំបូងគឺសាងប្រាសាទ កំពែង វលភី.."

"...ឱយ្យវ្រ៌្វទ្រវ្យតវ្រះនោះផោងឱយិខ្ញុំចោងវលភិចោងកំវេងអ្វេងថ្វេក្បេត្រារាមជ្យក្ត្រវាង.." អាចប្រែសម្រួលបានថា "...បានថ្វាយទ្រព្យរបស់ដល់ព្រះនោះទៀតផង ថ្វាយអ្នកបម្រើ សង់វលភី សង់កំពែងដោយថ្មបាយក្រៀម ធ្វើសួន"...ចម្ការ ជីកត្រពាំង-[៣]

តាមរយៈព័ត៌មានក្នុងសិលាចារឹកខាងលើនេះអាចឱ្យយើងដឹងថា "វលភី" ជាពាក្យបច្ចេកទេសមួយសំដៅដល់សំណង់មួយបែបដែលធ្វើឡើងជាមួយសំណង់ផ្សេងៗទៀត។ ពាក្យ "វលភី" លេចឡើងនៅក្នុងសិលាចារឹកជាច្រើនទៀតដូចជាសិលាចារឹកប្រាសាទគោកខាងត្បូង K.៨៨៧ សិលាចារឹកប្រាសាទព្រះខ័នK.908 សិលាចារឹកភ្នំស្រះ K.១០០២ សិលាចារឹកប្រាសាទតាព្រហ្ម K.២៧៣ និងសិលាចារឹកថ្មីដែលទើបតែរកឃើញនៅជើងភ្នំត្រប់[៤]ជាដើម។ សិលាចារឹកទាំងនេះចារឡើងនៅរវាងចុងស.វទី១០រហូតដល់ចុងស.វទី១២។ ជាងនេះទៅទៀត គេប្រទះឃើញអក្សរចារឹកនៅលើថ្មដែលគេយកមកសាងប្រាសាទចេតិយនៃក្រុមប្រាសាទព្រះខ័នកំពង់ស្វាយ ខេត្តព្រះវិហារ (**រូបលេខ៧**) ដោយអក្សរចារឹកនោះមានសេចក្តីថា៖ *(ប)តេកវលភិ (វ្រះ)ក* អាចប្រែសម្រួលបានថា៖ « ផ្តេក(នៅ)វលភី ព្រះគម្តែង(?)...»។[៥] លោក ហ៊ុន ឈុនតេង បានពន្យល់ឱ្យដឹងថា អក្សរថ្ម

---

[៣] វង់ សុជាវ៉ា ២០២១: ២៨៦-៣២២។

[៤] សូមអានបន្ថែមនៅ៖ https://ams.com.kh/khmercivilization/detail/19834

[៥] សូមថ្លែងអំណរគុណដល់លោក ហ៊ុន ឈុនតេង បេក្ខជនបណ្ឌិតខេមរសិក្សា នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលបានជួយផ្តល់ព័ត៌មានពីសិលាចារឹក និងបានជួយបកប្រែសិលាចារឹកនៅប្រាសាទចេតិយ។

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់

បែបនេះជាប្រភេទអក្សរដែលជាងសរសេរសម្រាប់សម្គាល់លើថ្មដើម្បីយកទៅសាងប្រាសាទ។ ការប្រទះឃើញពាក្យវលភិនៅទីតាំងប្រាសាទនេះ វាហាក់មានភាពស្រមគ្នាទៅនឹងលក្ខណៈសំណង់របស់ប្រាសាទចេតិយ ពោលគឺជាប្រាសាទទោល មានរាងចតុកោណកែង ដំបូលខាងលើបន្តស់បើទោះបីជាបាក់បែកអស់មួយភាគធំក៏ពិតមែន តែយើងក៏អាចសន្និដ្ឋានបានដែរថា ដំបូលប្រាសាទទំនងមានរាងកោងវែងមានសណ្ឋានដូចដំបូលទូក ហើយនៅចុងសងខាងនៃដំបូលនោះធ្វើជាហោជាងរាងក្រចកដែលមានទំហំធំដែរ(**រូបលេខ៨**)។ លក្ខណៈប្រាសាទដូចបានរៀបរាប់មកនេះបង្ហាញថា ប្រាសាទចេតិយមានលក្ខណៈទូទៅដូចប្រាសាទបែបវលភីឬសាលានៃសិល្បៈឥណ្ឌា ហើយករណីនេះត្រូវគ្នានឹងអក្សរថ្មីដែលជាងសរសេរសម្គាល់លើថ្មសម្រាប់យកមកសាងសង់នៅ "វលភី" ពោលគឺអាចសំដៅដល់ប្រាសាទចេតិយនោះឯង។

ជាសរុបមកសង្គមខ្មែរប្រហែលជាបានស្គាល់ទម្រង់ប្រាសាទបែបវលភីឬសាលានៃសិល្បៈឥណ្ឌាតាំងពីសម័យមុនអង្គរមកម្ល៉េះ។ ដោយនៅសម័យមុនអង្គរស្ថាបត្យកម្មខ្មែរទទួលឥទ្ធិពលយ៉ាងខ្លាំងពីទម្រង់ប្រាសាទបែបសាលានៃសិល្បៈឥណ្ឌាខាងត្បូង ជាពិសេសទទួលឥទ្ធិពលពីសិល្បៈបល្លវៈ។ ក្រោយមកនៅសម័យអង្គរស្ថាបត្យកម្មខ្មែរប្រហែលជាបានទទួលឥទ្ធិពលប្រាសាទបែបវលភីនៃស្ថាបត្យកម្មឥណ្ឌាខាងជើងមកជំនួសប្រាសាទបែបសាលានៃសិល្បៈឥណ្ឌាខាងត្បូងវិញ។ ហេតុនេះហើយទើបប្រាសាទដែលមានរាងចតុកោណកែង ដំបូលកោងវែងមានសណ្ឋានដូចដំបូលទូក និងមានហោជាងទាំងសងខាង ដែលនៅមុនសម័យអង្គរនិយមធ្វើដំបូលច្រើនជាន់ បែរជានិយមធ្វើដំបូលតែមួយជាន់ទៅវិញនៅសម័យអង្គរ៕

**បញ្ជីឯកសារយោង**

វង់ សុធារ៉ា.

២០២១. សិលាចារឹកកម្ពុជាសម័យអង្គរ, ភ្នំពេញ៖ ក្រសួងអប់រំយុវជននិងកីឡា។

អត្ថបទដោយ៖ ឡេង ស៊ីវ៉េង

ហ៊ុន ឈុនតេង.

២០២២. https://ams.com.kh/khmercivilization/detail/19834

Hardy, Adam.

2007. *The Temple Architecture of India*, Chichester: Wiley.

Tingsanchali, Chedha.

2016. *Shikhara and Vimanan in Indian art and their influences to Southeast Asian*, Development Institute, Silpakorn University.

## បញ្ជីរូបភាព



រូបលេខ១៖ ប្រាសាទភ្នំបាយ៉ង់ ស.វ.ទី៧
(រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ២៖ ប្រាសាទភូមិប្រាសាទ ស.វ.ទី៨
(រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ៣៖ ប្រាសាទគណេសរថ នៅទីក្រុងMahabalipuram សិល្បៈបល្លវៈ ស.វ.ទី៧ (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ៨៖ បណ្ណាល័យខាងជើងនៃប្រាសាទបន្ទាយស្រី ស.វ.ទី១០ (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ៩៖ បណ្ណាល័យខាងត្បូងនៃប្រាសាទបន្ទាយសំរែ ស.វ.ទី១២ (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់



រូបលេខ២៦៖ ប្រាសាទ Vaitala Deula នៃរដ្ឋអូរិសសា, សិល្បៈអូរិសសា ស.វ.ទី៨

(រូបថត៖ https://sarsonkekhet.in/2019/09/24/odisha-style-bhubaneswar-vaital-deul-and-shishireshwara-temples/)



រូបលេខ២៧៖ ចារឹកនៅមេទ្វារប្រាង្គខាងជើងនៃប្រាសាទចេតិយ (រូបថត៖ ឡេង ស៊ីវ៉ង់)



រូបលេខ២៨៖ ប្រាសាទចេតិយ នៃក្រុមប្រាសាទព្រះខ័នកំពង់ស្វាយ (រូបថត៖ ឡេង ស៊ីវ៉ង់)

អត្ថបទដោយ៖ ឡេង ស៊ីវ៉ង់